# ៨. សន្និដ្ឋាន

យោងលើលទ្ធផលនៃវាយតំលៃហេតុប៉ះពាល់បរិស្ថាននិងសង្គម នៅក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ច ដែលស្នើសុំដោយក្រុមហ៊ុន **បៀន ហៀក អ៊ិនវេសមេន**រួចមកក្រុមការងារបានធ្វើការសន្និដ្ឋាន ដូចខាងក្រោម:

**២២៤.** ជាទូទៅវាយនភាពដីនៅតំបន់សម្បទាននេះមានសិលាមេ៤ប្រភេទគឺ: (១) Floodplains (៣ហិកតា) ស្មើនឹង ០,០៧ភាគរយ (២) Lake bed deposits (១ហិកតា) ស្មើនឹង០,០២ ភាគរយ (៣) Pediments (៤៣៦៦ហិកតា) ស្មើនឹង ៩៩,៥៦ ភាគរយ និង(៤)Peneplain laterite deposits (១៥ហិកតា) ស្មើនឹង០,៣៤ភាគរយ នៃផ្ទៃដីសរុប នៅតំបន់ដីសម្បទាននេះមិនសូវសំបូរប្រភពទឹកស្រទាប់លើទេ ដែលនៅក្នុងទីតាំងនេះមានត្រពាំងពីរ ត្រពាំងធំស្ថិតនៅភាគខាងត្បូង និងត្រពាំងតូចនៅភាគខាងកើត ហើយបច្ចុប្បន្នទឹកស្រទាប់លើនៅតំបន់នោះ ពុំទាន់ទទួលរងនូវការបំពុលពីផ្នែកឧស្សាហកម្មនៅឡើយទេ។

**២២៥.** ទឹកស្រទាប់លើ: នៅតំបន់ដីសម្បទាននេះមិនសំបូរប្រភពទឹកស្រទាប់លើទេ។ តាមរយៈផែនទីប្រើប្រាស់ដី និងគំរបព្រៃបង្ហាញថា មានតែអូរតូច១ប៉ុណ្ណោះ គឺកោសលង់ (តាមអ្នកស្រុក រស់នៅក្នុងឃុំសាគ្រាមជើង ហៅថាអូរពលង់)។ ក្រៅពីអូរមួយនេះចេញ នៅសង្កេតឃើញមានត្រពាំងមួយឈ្មោះត្រពាំងធំ តែត្រពាំងនេះភាគច្រើនរីងនៅក្នុងចុងរដូវប្រាំង។

**២២៦.** មានប្រព័ន្ធមជ្ឈដ្ឋានប្រែស្ថិតនៅក្នុងតំបន់ទំនាបកណ្តាល ដែលក្នុងនោះរាប់បញ្ចូលទាំងតំបន់ផលិតកម្មកៅស៊ូសំខាន់ៗ ហើយបង្កើតបានជាប្រព័ន្ធមជ្ឈដ្ឋានប្រែរបស់តំបន់ទំនាបកណ្តាលធំជាងគេ (១៨ភាគរយ)។ តំបន់ទំនាបនេះគឺអាងស្តុកទឹកសំខាន់មុនហូរចាក់ចូលទៅក្នុងទន្លេសាប និងទន្លេមេគង្គ។ តំបន់នេះផ្នែកខាងត្បូង បញ្ចប់នឹងតំបន់ដីក្រហម ខាងជើងជាប់នឹងភ្នំដងរែក ខាងលិចជាប់នឹងតំបន់ទំនាបខាងជើង និងខាងកើតជាប់នឹងតំបន់ទំនាបទន្លេមេគង្គផ្នែកខាងកើត។ តំបន់នេះមានលក្ខណៈខុសពីតំបន់ដីទៃទៀតដោយសារកំពស់ទឹកភ្លៀងទាប ហើយដីមានប្រភេទដីដូចៗគ្នា។

**២២៧.** តាមរយៈរូបភាព Photo Index Maps នៅលើចំណុចទាំង០៦ Photo Index A, B, C, D, E, F បង្ហាញអោយឃើញថា គំរបព្រៃ និងធនធានព្រៃឈើមានលក្ខណៈ ជាព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង ព្រៃល្បោះ និងប្រភេទព្រៃផ្សេងៗ នឹងដីគ្មានព្រៃ។ ព្រៃដែលដុះនៅក្នុងទីតាំងទាំងនោះពិនិត្យ ឃើញមានតម្លៃពាណិជ្ជកម្មមធ្យម។ តែតាមការពិនិត្យ លំអិតទៅលើរូបភាព Photo Index E និង F បង្ហាញថា ស្ថានភាពគំរបនិង ធនធានព្រៃឈើមានលក្ខណៈបង្គួរ តែកន្លែងខ្លះព្រៃដុះរហោលៗកន្លែងខ្លះក្រាស់ ពុំទាន់ទទួលរងការកាប់រានដីនៅឡើយ។ ចំពោះ Photo Index A, B និង C បង្ហាញថា ស្ថានភាពគំរប និងធនធានព្រៃឈើនៅទីនោះមានការបាត់មួយចំនួនធំ ដីដែលគ្មានព្រៃ គឺជាដីដែលប្រជាពលរដ្ឋក្នុងតំបន់ធ្វើការរាន និង កាប់ឆ្ការ

Draft

ដើម្បីដាំដំណាំជាច្រើនឆ្នាំ និងខ្លះទៀតទើបកាប់ហើយកាលពីរដូវប្រាំងកន្លងទៅនេះ។ ព្រៃដែលមាននៅសេសសល់ក្នុងតំបន់នេះស្ទើរតែបាត់បង់តម្លៃពាណិជ្ជកម្មទាំងស្រុងហើយ។

**២២៧.** ការសិក្សាទៅលើរូបភាពនេត្រាទស្សន៍-១ អំពីស្ថានភាពនៃការប្រើប្រាស់ដីក្នុងតំបន់ដីសម្បទាន បង្ហាញថា ព្រៃឈើទាំងនេះមានលក្ខណៈជាព្រៃចំរុះ ស្ថានភាពគំរបព្រៃមានលក្ខណៈបង្គួរ និងមានការរំខានពីការកាប់រានធ្វើចំការរបស់ប្រជាជននៅរួចទៅហើយ។ ចំពោះរូបភាពនេត្រាទស្សន៍-២ សង្កេតឃើញ មានដីវាលដុំៗដូចគ្នានឹង-១ ដែរ ដោយឃើញមានសំណាក ចំការចាស់ផងដែរ (ជាចំការបុស្ស) របស់ប្រជាជនក្នុងមូលដ្ឋាន។ ការជួបសន្ទនាជាមួយនឹងអាជ្ញាធរមូលដ្ឋាន និងប្រជាជនបានអោយដឹងថានៅក្នុងតំបន់ដូចបានរៀបរាប់ខាងលើនេះពិតជាមានដីចំការចន្ទី និងដីស្រែចំការចាស់របស់ពួកគាត់មែន។ ពួកគាត់បានសំណូមពរថា ក្រុមហ៊ុនត្រូវធ្វើការដោះស្រាយនូវរាល់ផ្ទៃដីស្រែ-ចំការដែលពាក់ព័ន្ធ ជាមុនសិនមុននឹងធ្វើការឈូសឆាយ។

**២២៨.** នៅក្នុងប្រភេទព្រៃស្រោងរបស់តំបន់សម្បទាន មានរុក្ខជាតិចំនួន ៩៨ប្រភេទ ជុល្លិព្រឹក្ស៥៥ប្រភេទ និងតិណជាតិចំនួន៦៨ប្រភេទ។ ភាពសម្បូរណ៍បែប និងសមាសភាពនៃរុក្ខជាតិ ទាំងនោះត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយក្នុងការពន្យល់បកស្រាយពីរចនាសម្ព័ន្ធទីជំរកដោយលោក Scweithelm and Chhay 2007 ដោយបាននិយាយថា នៅក្នុងព្រៃល្បោះគ្របដណ្តប់ដោយប្រភេទរុក្ខជាតិ ដូចជា ខ្លុង ត្បែង ធ្នឹក រាំងភ្នំ នាងផ្អែក ក្នុងពេលដែលពពួកស្បូវ និងស្មៅព្រិច ជាពពួករុក្ខជាតិថ្នាក់ក្រោម។ ការសិក្សាបានបង្ហាញថា មានសត្វស្លាបចំនួនភាពសំបូរបែបនៃសត្វស្លាបដែលបានកត់ត្រានៅក្នុងតំបន់សិក្សាស្រាវជ្រាវ គឺមានចំនួនស្មើនឹង ៦៤ភាគរយ នៃលទ្ធផលដែលទទួលបានពីការសំភាសន៍ជាមួយប្រជាជនមូលដ្ឋាន រស់ក្បែរតំបន់ស្រាវជ្រាវ នឹងត្រូវជា០៦ភាគរយ នៃចំនួនសត្វស្លាបសរុបក្នុងប្រទេសកម្ពុជា។ ចំណែកឯ មានថនិកសត្វចំនួន ០៦ប្រភេទ ដែលជួបប្រទះនៅក្នុងតំបន់ដីគំរោងវិនិយោគ ហើយថនិកសត្វដែលកត់ត្រាបាន មានចំនួនប្រមាណ២៨,៥៧ ភាគរយនៃចំនួនសត្វដែលបានពីការសំភាសន៍ប្រជាជនមូលដ្ឋាន ហើយត្រូវជា ២,៧៥ភាគរយ នៃចំនួនថនិកសត្វសរុបនៅក្នុងប្រទេសកម្ពុជា។ ចំពោះមច្ឆាជាតិវិញ នៅក្នុងតំបន់សម្បទាននេះ មិនសំបូរប្រភពទឹកស្រទាប់លើទេ ក្រៅពីអូរតូចៗពីរគឺ អូរដូងគ្រាច និង អូរកោសលង់ មានតែត្រពាំងចំនួន ០៥ដែលរីងនៅចុងរដូវប្រាំង។ តាមការសាកសួរពីប្រជាជនមូលដ្ឋាន បញ្ជាក់ថា ពួកគាត់ធ្លាប់នេសាទបាននូវ ប្រភេទត្រីមួយចំនួន (ទាំងប្រភេទត្រីស និងត្រីខ្មៅ) នៅក្នុងតំបន់នោះគឺ ត្រីឆ្ពិន ត្រីចង្វាជញ្ជាត់ដៃ ត្រីស្រកា ក្ដាម ត្រីក្រោស...។

**២២៩.** ផលិតផលចំការស្វាយចន្ទី ជាប្រភពចំណូលសំខាន់របស់គ្រួសារនីមួយៗ។ តែផ្ទៃដីសំរាប់ធ្វើស្រែមានតិចតួចមិនអាចផ្គត់ផ្គង់ឱ្យគ្រប់គ្រួសារឡើយ គ្រួសារដែលគ្មានដីស្រែបានទៅរានដីធ្វើចំការទៅតាមលទ្ធភាពរៀងៗខ្លួន។ គ្រួសារភាគច្រើន ដាំស្វាយចន្ទី ទិន្នផលនៃមុខដំណាំនេះអាចធ្វើឱ្យប្រជាជននៅក្នុងតំបន់នេះមានជីវភាពធូរធារមួយកំរិត ក្នុងរយៈពេលពីឆ្នាំមុននេះ(២០០៩) ដែលតំលៃក្នុង១គីឡូក្រាមលក់បានក្នុងតំលៃ ២៥០០-៣០០០រៀល។ ក្រៅពីនោះ ពួកគាត់ប្រកបរបរកាប់អុស និងកាប់ឈើនៅក្នុងតំបន់អភិរក្ស។ ចំណូល

ដែលបានមកពីការធ្វើចំការ និងចំការស្វាយចន្ទីនេះក៏នៅតែមិនអាចទ្រទ្រង់នូវជីវភាពក្នុងគ្រួសាររបស់ពួកគាត់ល្អទេ ព្រោះគ្រួសារភាគច្រើនមានសមាជិកច្រើន ហើយការដាំដំណាំចន្ទីរបស់ពួកគាត់មានលក្ខណៈជាយថាផល ចំណែកឯទិន្នផលស្រូវដែលទទួលបាន នៅមានកំរិតទាបនៅឡើយគិតជាមធ្យមគឺ១-១.៥ តោន ក្នុង១ឆ្នាំមួយហិកតាចំពោះស្វាយចន្ទីមាន៥០០-៧០០ដើម/ហិកតា) ដូចនេះមួយឆ្នាំអាចទទួលបានប្រមាណ ២.៥០០.០០០-៣.១៥០.០០០រៀល ។

**២៣១.** សេដ្ឋកិច្ចក្នុងតំបន់មានលក្ខណៈជាសេដ្ឋកិច្ចជនបទ លើកលែងតែទីរួមខេត្តចេញ ដែលការប្រកបរបរមានទ្រង់ទ្រាយពាណិជ្ជកម្ម ។ ចំណូលប្រចាំឆ្នាំរបស់គ្រួសារក្នុងសហគមន៍មានលក្ខណៈផ្សេងៗគ្នាអាស្រ័យទៅនឹងការប្រកបមុខរបររបស់គ្រួសារនីមួយៗ ។ ការវាយតំលៃអំពីភាពក្រីក្របានបង្ហាញថា អាត្រានៃភាពក្រីក្រនៅក្នុងខេត្តកំពង់ធំមាន: ២៩.១០ភាគរយ (១៥៨,៩ភាគពាន់) លើចំនួនប្រជាជនសរុប៦២១,៨៣៣នាក់ ភាគច្រើនរស់នៅជនបទ (៩៩ភាគរយ) (ផែនទីភាពក្រីក្ររបស់កម្មវិធីស្បៀង អង្គការសហប្រជាជាតិឆ្នាំ ២០០៥-២០០៦ និងប្រព័ន្ធទិន្នន័យសហគមន៍ឆ្នាំ២០០៤) ។

**២៣២.** លទ្ធភាពនៃការប្រើប្រាស់សេវាសាធារណៈ (គមនាគមន៍, អគ្គិសនី , ការផ្គត់ផ្គង់ទឹកស្អាត , អប់រំ និង សុខាភិបាល) នៅក្នុងសហគមន៍នេះស្ថិតនៅក្រោមបន្ទាត់នៃតម្រូវការ ។ ការចុះសិក្សាអង្កេតដោយផ្ទាល់បានបង្ហាញថា ផ្លូវគមនាគមន៍ដ៏សំខាន់សំរាប់ប្រជាពលរដ្ឋឃុំសាគ្រាម ធ្វើដំណើរ និងដឹកជញ្ជូនទំនិញផ្សេងៗគឺផ្លូវជាតិលេខ៦ ពីកំពង់ធំមកកាន់ស្រុកប្រាសាទបាល័ង្គ ដែលជាផ្លូវសំខាន់នៅតំបន់នោះ ។ ប្រជាជនដែលរស់នៅក្នុងឃុំសាគ្រាមពុំបានទទួលការផ្គត់ផ្គង់អគ្គិសនីជាមូលដ្ឋានទេ ។ លទ្ធភាពនៃការប្រើប្រាស់ថាមពលក្នុងការដុតបំភ្លឺរបស់ប្រជាជននៅក្នុងតំបន់នេះមានកំរិតទាប ដោយពួកគាត់ភាគច្រើនប្រើចង្កៀងប្រេងកាត និងចន្លុះសំរាប់បំភ្លឺ ហើយមានប្រជាជនមួយចំនួនតូចប៉ុណ្ណោះមានលទ្ធភាពប្រើអាគុយ ។ ដោយឡែកនៅក្នុងឃុំទាំងមូលមានម៉ាស៊ីនភ្លើង៦គ្រឿង ម៉ាស៊ីនទាំងនេះពួកគាត់ប្រើសំរាប់បញ្ចូលអាគុយ និងសំរាប់តបំភ្លឺនៅពេលយប់តាមផ្ទះ (បញ្ចេះពីម៉ោង៦ល្ងាច ដល់ម៉ោង១០យប់) និងដាក់បញ្ចាំងវីដេអូក្នុងតូបលក់កាហ្វេ ។ មានគ្រួសារប្រមាណ ៥០ភាគរយមានវិទ្យុប្រើប្រាស់ ។ ចំណែកឯការចំអិនអាហារវិញ គឺពួកគាត់ប្រើអុសដែលរកបានពីព្រៃនៅក្បែរភូមិចំងាយប្រហែលពី០,៥-១គ.ម ។

**២៣៣.** ការធ្វើដំណើរ និងដឹកជញ្ជូននៅក្នុងតំបន់គំរោងភាគច្រើនគឺប្រើប្រាស់ផ្លូវជាតិលេខ៦(ភ្នំពេញ-កំពង់ធំ) និង(កំពង់ធំ-ស្រុកប្រាសាទបាល័ង្គ) តាមផ្លូវជាតិលេខ៦២ រីឯផ្លូវដែលតភ្ជាប់ផ្លូវជាតិទៅនឹងសហគមន៍ពួកគាត់ជាផ្លូវលំក្រាលគ្រួសក្រហមកសាងដោយមូលនិធិរបស់ឃុំ ហើយផ្លូវមួយចំនួនទៀតជាផ្លូវរទេះ ឬផ្លូវលំដើរដោយជើង ផ្លូវទាំងនេះនៅក្នុងរដូវវស្សាមានសភាពរអិលពិបាកធ្វើដំណើរ តែមានភាពងាយស្រួលជាង២-៣ឆ្នាំមុន ។ដោយសារតែការធ្វើដំណើរចេញចូលមានលក្ខណៈល្អប្រសើរ ដូច្នេះហើយទើបធ្វើឱ្យការប្រាស្រ័យទាក់ទងរវាងសហ

Draft

គមន៏ទាំងនេះជាមួយនឹងតំបន់ខាងក្រៅមានលក្ខណៈទូលំទូលាយ និងទទួលបានការយកចិត្តទុកដាក់ជាមធ្យម ផងដែរ ពីបណ្តាភ្នាក់ងារអភិវឌ្ឍន៏ផ្សេងៗ ដែលក្នុងនោះមានការផ្គត់ផ្គង់ទឹកស្អាត និងសាលារៀន ជាដើម ។

## ៩. អនុសាសន៍

យោងលើសេចក្តីសន្និដ្ឋានស្តីពីហេតុប៉ះពាល់បរិស្ថាននិងសង្គម ក្រុមការងារសូមផ្តល់នូវអនុសាសន៍មួយចំនួនដូចខាងក្រោមៈ

**២៣៤.** នៅក្នុងដំណើរប្រតិបត្តិការគំរោង សាម៉ីវិនិយោគិន ត្រូវតែអនុវត្តផែនការគ្រប់គ្រងបរិស្ថានទៅតាមវិធានការណ៍នានាដូចមានកំណត់នៅក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម និងផែនការគ្រប់គ្រងបរិស្ថាន ដូចបានពណ៌នានៅក្នុងតារាង ៦-១ និងតារាង៦-២ នោះស្ថាប័នជំនាញ និងអាជ្ញាធរពាក់ព័ន្ធ ត្រូវតាមដានពិនិត្យនិងវាយតំលៃទៅលើសកម្មភាពនៃការអភិវឌ្ឍន៍របស់វិនិយោគិន ជាប្រចាំទៅតាមកម្មវិធីដូចមានកំណត់នៅក្នុងផែនការគ្រប់គ្រងបរិស្ថាន ។

| | |
|---|---|
| ភ្នំពេញ, ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១០ | ភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ ២០១០ |
| **នាយក** | **នាយកក្រុមហ៊ុន** |
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ឧបទេសកម្មបៃតង Green Consultancy Firm KINGDOM OF CAMBODIA

បណ្ឌិត. លី_សុពណ៌_មុនី

Draft